ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
លេខ....៩០២/១០...ក.អ.ក / គ.ជ.នា

រាជធានីភ្នំពេញ ថ្ងៃទី..២១.....ខែមេសា..ឆ្នាំ២០១០

**គោរពជូន**

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : សំណើសុំអនុមតិលើ «ខ្លឹមសារសង្ខេបប្រតិបត្តិនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០១០ (Cambodia Aid Effectiveness Report 2010)» និង «តារាងសូចនាករតាមដានរួមគ្នា (Joint Monitoring Indicators-JMI Matrix) » សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ (3rd Cambodia Development Cooperation Forum-CDCF)

**យោង** : សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧៤ សសរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងសម្របសម្រួលវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣

**ឯកសារភ្ជាប់**:- ខ្លឹមសារសង្ខេបប្រតិបត្តិនៃសេចក្តីព្រាងរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា

- តារាងសូចនាករតាមដានរួមគ្នា សម្រាប់ CDCF

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ និងផ្អែកតាមការប្រគល់ភារកិច្ចឱ្យខ្ញុំ ជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដឹកនាំនិងសម្របសម្រួលការងារត្រៀមរៀបចំវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ដែលនឹងប្រារព្ធធ្វើនាថ្ងៃទី០២- ០៣ ខែមិថុនា ឆ្នាំ២០១០ ខ្ញុំសូមរាយការណ៍ពីវឌ្ឍនភាពការងារសម្រាប់វេទិកានេះ បន្ទាប់ពីរបាយការណ៍លើកទី១ ជូន **សម្តេច នាយករដ្ឋមន្ត្រី** នាថ្ងៃទី១១ ខែមិនា ឆ្នាំ២០១០ ដូចតទៅ ÷

I- <u>សេចក្តីព្រាងកម្មវិធីសម្រាប់វេទិកា</u> : បន្ទាប់បានធ្វើការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល យើងបានឯកភាពលើប្រធានបទគន្លឹះសម្រាប់វេទិកាលើកទី៣នេះ គឺ *«ការអនុវត្តន៍ឱ្យបានសម្រេចនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព- ដំណាក់កាលទី២ តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម»* ។ លើសពីនេះ អង្គប្រជុំអន្តរក្រសួងកាលពីថ្ងៃទី០៤ ខែមិនា ក៏បានឯកភាពលើរបៀបវារៈសំខាន់ៗរបស់វេទិកា និងបានឯកភាពកំណត់ស្ថាប័នទទួលខុសត្រូវរៀបចំបទបង្ហាញក្នុងវេទិកា ។ បន្ទាប់មក ខ្ញុំបានផ្ញើសេចក្តីព្រាងកម្មវិធីនេះដៃគូអភិវឌ្ឍន៍ ហើយតាមរយៈកិច្ចប្រជុំរបស់ខ្លួន កាលពីថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១០ ដៃគូអភិវឌ្ឍន៍បានឯកភាពជារួមលើសេចក្តីព្រាងនេះ ។ ទន្ទឹមនឹងនេះ ពួកគេក៏បានស្នើចំណុចមួយចំនួន ២ សម្រាប់បញ្ចូលបន្ថែមក្នុងរបៀបវារៈរបស់វេទិកាលើកទី៣ (CDCF) គឺ÷

១- វិលេចលទ្ធផលនៃ «វេទិការវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន» ដែលនឹងប្រារព្ធទៅ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ទៅក្នុងវេទិកាលើកទី៣ ។ យើងអាចបញ្ចូលចំណុចនេះទៅក្នុងរបៀបវារៈទី២ ស្តីពី«ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច» ។

២- ការអនុវត្តន៍អាទិភាព និងកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ដូចជាវឌ្ឍនភាពក្នុងការអនុវត្តន៍គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ពិសេសក្នុងវិស័យសង្គមកិច្ច កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ការធ្វើសមាហរណកម្មរវាងផែនការ ថវិកានិងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងដីធ្លី ។ ខ្ញុំយល់ថា ចំណុចស្ទើរតែទាំងអស់ត្រូវបានរំលេចរួចហើយនៅតាមរបៀបវារៈនីមួយៗនៃវេទិកា ។ រីឯចំណុចសេសសល់ចំនួន២គឺ កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ និងការគ្រប់គ្រងដីធ្លី ក៏អាចបញ្ចូលទៅជាកម្មវត្ថុនៃការពិភាក្សាក្នុងរបៀបវារៈទី១ «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម» ។ ដូចនេះ យើងបានដោះស្រាយកង្វល់ទាំងអស់ដែលដៃគូអភិវឌ្ឍន៍បានលើក ។

II- <u>របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា</u> : នេះជាលើកទី៣ ដែលរាជរដ្ឋាភិបាល ដោយមាន គ.ជ.នា/ក.អ.ក ជាលេខាធិការដ្ឋាន បានរៀបចំរបាយការណ៍នេះសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ក្នុងរយៈពេលជិត២ខែកន្លងមក ។ របាយការណ៍លើកនេះបានបូកសរុបអំពីវឌ្ឍនភាព និងបានវិភាគនិន្នាការនៃកិច្ចសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍ ព្រមទាំងលើកឡើងនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតសម្រាប់បន្តពង្រឹងភាពជាដៃគូ ។ លើសពីនេះ របាយការណ៍ក៏បានពិនិត្យលើបរិមាណនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងបានវិភាគបន្ថែមលើប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានទាំងនេះសម្រាប់គាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ជំពូកមួយចំនួននៃរបាយការណ៍នេះដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសចម្រុះទាំង១៩ ត្រូវបានពិភាក្សាលំអិតនៅក្នុងអង្គសិក្ខាសាលា ដែលដឹកនាំដោយឯកឧត្តម **ឈៀង យ៉ាណារ៉ា** កាលពីថ្ងៃទី០៧-០៩ ខែមេសា នៅខេត្តសៀមរាប ។ ផ្អែកលើយោបល់ និងអនុសាសន៍ គ.ជ.នា/ក.អ.ក បានរៀបចំបញ្ចប់សេចក្តីព្រាងរបាយការណ៍នេះ ។ ដោយរបាយការណ៍នេះមានច្រើនទំព័រ យើងបានរៀបចំជាខ្លឹមសារសង្ខេបប្រតិបត្តិ ហើយសូមដាក់ខ្លឹមសារសង្ខេបនេះជូន **សម្តេច នាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចផ្តល់ការឯកភាពជាគោលការណ៍លើខ្លឹមសារសង្ខេបនេះ ដើម្បីឱ្យខ្ញុំមានលទ្ធភាពផ្តល់ជូនទៅដៃគូអភិវឌ្ឍន៍ សម្រាប់ឱ្យពួកគេស្វែងយល់ឱ្យបានច្បាស់បន្ថែមទៀត អំពីកិច្ចប្រឹងប្រែងកន្លងមក និងកិច្ចការដែលត្រូវរួមគ្នាអនុវត្តបន្ត ក៏ដូចជាទទួលធាតុចូលជាយថាហេតុបន្ថែមទៀត ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) ដែលគ្រោងធ្វើនាថ្ងៃទី២៩ខែមេសាឆ្នាំ២០១០ខាងមុខនេះ ។ បន្ទាប់មក គ.ជ.នា/ក.អ.ក នឹងបោះពុម្ពរបាយការណ៍នេះ ដើម្បីចែកផ្សព្វផ្សាយជូនបណ្តាក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិល ឱ្យបាន២សប្តាហ៍មុនវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣នេះ ។

III- <u>សូចនាករតាមដានរួមគ្នាថ្មី (New Joint Monitoring Indicators-JMIs)</u>

ដូចសព្វមួយដង វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣នេះនឹងអនុមតិលើតារាងសូចនាករតាមដានរួមគ្នាថ្មី សម្រាប់អនុវត្ត និងតាមដានរួមគ្នាអំពីវឌ្ឍនភាពក្នុងចន្លោះពី CDCF លើកទី៣នេះ និង

CDCF លើកទី៤ ។ ក្នុងការរៀបចំ គ.ជ.នា/ក.អ.ក បានទទួលសំណើពីក្រុមការងារបច្ចេកទេសចម្រុះចំនួន១៨ និងអង្គភាពប្រឆាំងអំពើពុករលួយ ហើយបានធ្វើសំយោគដូចមានតារាងជូនភ្ជាប់មកជាមួយនេះ ។ សូចនាករតាមដានរួមគ្នាបានឆ្លុះបញ្ចាំងសកម្មភាពគន្លឹះតាមវិស័យអាទិភាពនៃ «យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២» ។ លើសពីនេះ ការរៀបចំសូចនាករថ្មីនេះក៏បានប្រើប្រាស់ទម្រង់ថ្មីរបស់ គ.ជ.នា/ក.អ.ក ដើម្បីរំលេចឱ្យឃើញនូវសង្វាក់ទាក់ទងរវាងសកម្មភាពគន្លឹះទៅនឹងលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ (Development Results) ។ សូចនាករតាមដានរួមគ្នាទាំងនេះត្រូវបានពិភាក្សាលំអិត និងបានផ្តល់សុពលភាពនៅក្នុងអង្គវិបស្សនាកាលពីថ្ងៃទី០៧- ០៩ ខែមេសា នៅខេត្តសៀមរាបផងដែរ លើកលែងតែសូចនាករដែលពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈដែលអាចស្នើឡើងនាចុងខែមេសានេះ ។ ខ្លឹមសារដូចបានជម្រាបជូនខាងលើ ខ្ញុំសូមស្នើ **សម្តេច នាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចផ្តល់ការឯកភាពជាគោលការណ៍លើតារាងសូចនាករតាមដានរួមគ្នា សម្រាប់ដាក់ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាង រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) ដែលគ្រោងធ្វើនាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ខាងមុខនេះ ដើម្បីពិភាក្សានិងឯកភាព មុននឹងត្រូវអនុម័តក្នុងវេទិកាលើកទី៣ ។ ក្នុងករណីដៃគូអភិវឌ្ឍន៍មានបំណងស្នើកែសម្រួល ឬផ្លាស់ប្តូរគោលដៅ ឬសកម្មភាពណាមួយ ដៃគូអភិវឌ្ឍន៍នោះចាំបាច់ត្រូវពិភាក្សាជាមុនជាមួយតំណាងសម្របសម្រួលរបស់ខ្លួនប្រចាំក្រុមការងារបច្ចេកទេសចម្រុះដែលពាក់ព័ន្ធ (TWG Lead Facilitator) ហើយត្រូវទទួលបាននូវការឯកភាពពីប្រធានក្រុមការងារបច្ចេកទេសចម្រុះជាមុនសិន ទើបអាចកែសម្រួលបាន ។ អនុវត្តតាមគោលការណ៍នេះ ទើបយើងរក្សាបាននូវតម្លៃរបស់យន្តការ «ក្រុមការងារបច្ចេកទេស ចម្រុះ» អាចពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំបាន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **សម្តេច នាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ និងមេត្តាផ្តល់ការណែនាំជាយថាហេតុដ៏ខ្ពង់ខ្ពស់តាមការគួរ ។

សូម **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តា ទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**

ចម្លងជូន :
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ឯកសារ

24.4.10